# ខ្មែរក្រហមក្នុងពេលអតីតកាលនិងបច្ចុប្បន្នកាល
# រូបថតប្រវត្តិសាស្ត្រ

### *ការតាំងពិព័រណ៍រូបថតស្តីអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម នៅសាកលវិទ្យាល័យរ៉ាត់ហ្គើត សហរដ្ឋអាមេរិក*
### *ពីថ្ងៃទី២៨ ខែមីនា ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៦*
### *រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំការងារដោយសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន នៅវិទ្យាស្ថានសិក្សាសង្គមនិងនរវិទ្យា*

បក្សកុម្មុយនិស្តកម្ពុជា (ប្រជាជនហៅថាខ្មែរក្រហម) បានកាន់កាប់ប្រទេសកម្ពុជាចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រោយការដឹកនាំរបស់ ប៉ុល ពត គណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។ មិនដល់បួនឆ្នាំផង ប្រជាជនកម្ពុជាប្រមាណពីរលាននាក់ត្រូវបានប៉ាន់ស្មានថាបាត់បង់ជីវិតដោយសារកង្វះអាហារ ធ្វើការហួសកម្លាំង ជំងឺគ្មានថ្នាំសង្កូវព្យាបាល និងការសម្លាប់ ។ មួយភាគបួននៃប្រជាជនសរុបបានបាត់បង់ជីវិតក្នុងរបបនោះ ។ នេះគឺអំពើប្រល័យពូជសាសន៍ដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្របើគិតពីអត្រាមនុស្សស្លាប់ធៀបនឹងចំនួនប្រជាជនសរុប ។

រូបថតដែលបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៧០ ដែលកំពុងតែដាក់បង្ហាញនៅទីនេះ ត្រូវបានយកចេញពីបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការស្រាវជ្រាវឯករាជ្យមិនមែនរដ្ឋាភិបាលដែលរក្សាទុកសំណៅឯកសារដើមពីរបបកម្ពុជាប្រជាធិបតេយ្យច្រើនបំផុតនៅលើពិភពលោក ។ រូបថតទាំងនេះគឺជារូបបុរសនិងស្ត្រីចំនួន១២នាក់អាយុចន្លោះពី១៤ទៅ២៩ឆ្នាំ ដែលសុទ្ធតែធ្លាប់បានចូលរួមបម្រើបដិវត្តន៍ខ្មែរក្រហម ។ អ្នកទាំង១២នាក់ជាអតីតយុទ្ធជន យុទ្ធនារី ឬជាអ្នកបម្រើការនៅក្នុងមន្ទីរសន្តិសុខមជ្ឈិម ស-២១ ។ តាមការប៉ាន់ស្មាន ក្នុងចំណោមអ្នកទោសជាងមួយម៉ឺនបួនពាន់នាក់ដែលជាប់នៅក្នុងមន្ទីរសន្តិសុខនោះ មានតែ១២នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។

រូបថតកម្មាភិបាលខ្មែរក្រហមថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភាគច្រើនមានភ្ជាប់មកជាមួយនូវ“ប្រវត្តិរូប”ដែលកម្មាភិបាលម្នាក់ៗបានធ្វើយ៉ាងតិចក៏ម្តងដែរ ។ នៅក្នុងប្រវត្តិរូបមានកត់ត្រាព័ត៌មានអំពីអាយុ ភូមិកំណើត សមាជិកគ្រួសារ វណ្ណៈសង្គម និងមូលហេតុដែលកម្មាភិបាលរូបនេះចូលបម្រើបដិវត្តន៍ ។ ដោយប្រើប្រាស់ព័ត៌មាននៅក្នុងប្រវត្តិរូប បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញអតីតកម្មាភិបាលខ្មែរក្រហមទាំង១២រូប និងបានថតរូបនិងធ្វើសម្ភាសន៍អំពីបទពិសោធន៍និងទស្សនៈរបស់គាត់ជុំវិញការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ពិព័រណ៍នេះត្រូវបានរៀបចំឡើងដោយសមាជិកនៃសិក្ខាសាលាជាន់ខ្ពស់ស្តីអំពីយុត្តិធម៌អន្តរកាលរបស់មហាវិទ្យាល័យអនទើ ក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន ។ សាកលវិទ្យាល័យរ៉ាត់ហ្គើត-ញូវវីក បានរក្សាទុកឯកសារនិងសម្ភារផ្សេងៗទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯកសារទាំងនោះរួមមានឯកសារខ្មែរក្រហម ម៉ៃក្រូហ្វីល ខ្សែភាពយន្ត ផែនទី ប៉ាំណូ រូបថត និងឯកសារដែលបោះពុម្ពផ្សាយដោយរបបខ្មែរក្រហម ឬនៅក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច ។

យើងសង្ឃឹមថា ចំណេះដឹងអំពីបទពិសោធន៍របស់ប្រជាជនកម្ពុជាអាចយកទៅអនុវត្តជាមួយអំពើប្រល័យពូជសាសន៍ដែលកើតមាននៅទីកន្លែងផ្សេងទៀតជុំវិញពិភពលោក ។ សាស្ត្រាចារ្យ អាឡិច ហ៊ីនតុន មានប្រសាសន៍ថា “ជនដែលមិនមែនជាប្រជាជនកម្ពុជាមិនអាចយល់ច្បាស់ថាតើការឆ្លងកាត់អំពើប្រល័យពូជសាសន៍មានន័យដូចម្តេចទេ ក៏ប៉ុន្តែនេះមិនមែនមានន័យថាអ្នកទាំងនោះនឹងមិនយល់អំពីមូលហេតុដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍ឡើយ ។ យើងរៀបចំការតាំងពិព័រណ៍រូបថតនេះពីព្រោះកិច្ចការនេះមានសារសំខាន់ចំពោះយើង ។ ការសិក្សាពីអំពើប្រល័យពូជសាសន៍ក៏បានផ្តល់ជាមេរៀនដល់យើងអំពីជីវិតរបស់យើង និងអំពីពិភពលោកដែលនៅជុំវិញយើង” ។

ការតាំងពិព័រណ៍នេះប្រព្រឹត្តទៅក្រោមក្រោមការគាំទ្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណាល័យ ចន កូជិន ខែនណា និងសមាគមអតីតនិស្សិតនៃសាកលវិទ្យាល័យរ៉ាត់ហ្គើត-ញូវវីក និង មូនិធិរ៉ាត់ហ្គើត ។

**ប្រែសម្រួលដោយ ប៉ាន់ ស៊ីម៉ាឡា**